ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

លេខ: ២៧៧០១ វ.ប.ក

# សេចក្តីជូនដំណឹងបន្ថែម

## ស្តីពីការជ្រើសរើសនិស្សិតចូលរៀនឆ្នាំទី១ កម្រិតបរិញ្ញាបត្ររងវិស្វកម្ម នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (រាជធានីភ្នំពេញ) សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

**I. ចំនួនជ្រើសរើស ៖**

នៅឆ្នាំសិក្សា ២០២២-២០២៣ នេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (រាជធានីភ្នំពេញ) នឹងជ្រើសរើសនិស្សិតកម្រិតបរិញ្ញាបត្ររងវិស្វកម្ម សិក្សារយៈពេល២ឆ្នាំ តាមមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ដូចខាងក្រោម ៖

| មហាវិទ្យាល័យឬដេប៉ាតឺម៉ង់ | ចំនួនសរុប | អាហារូបករណ៍រដ្ឋ | អាហារូបករណ៍ S4C |
|---|---|---|---|
| គីមីឧស្សាហកម្ម | ២០០ នាក់ | ១៥% | ៣០% |
| សំណង់ | ២០០ នាក់ | ១៥% | ៣០% |
| បច្ចេកទេសអគ្គិសនី | | | |
| ឯកទេសអគ្គិសនី | ១៥០ នាក់ | ១៥% | ៣០% |
| ឯកទេសអេឡិចត្រូនិច | ១៥០ នាក់ | ១៥% | ៣០% |
| ឯកទេសមេកាត្រូនិច | ១៥០ នាក់ | ១៥% | ៣០% |
| ឧស្សាហកម្ម និងមេកានិក | | | |
| ឯកទេសឧស្សាហកម្មនិងមេកានិក | ១៥០ នាក់ | ១៥% | |
| ឯកទេសបន្សុីលោហៈ | ១៥០ នាក់ | ១៥% | ៣០% |
| រ៉ែ និងភូគព្ភសាស្ត្រ | ៥០ នាក់ | ១៥% | |
| វារីសាស្ត្រ | ៥០ នាក់ | ១៥% | |

អាហារូបករណ៍រដ្ឋ (ចំនួន ១៥% នៃចំនួននិស្សិតសរុបជាក់ស្តែង) គឺជាប្រភេទអាហារូបករណ៍មិនបង់ថ្លៃសិក្សា ១០០% សម្រាប់រយៈពេល ០២ឆ្នាំ។ អាហារូបករណ៍នេះនឹងត្រូវបែងចែកក្រោយពេលចូលរៀន។ អាហារូបករណ៍នេះនឹងត្រូវកាត់ផ្តាច់នៅពេលនិស្សិតរៀនត្រួតថ្នាក់។

អាហារូបករណ៍គម្រោង S4C (ចំនួន ៣០% នៃចំនួននិស្សិតសរុបជាក់ស្តែង) គឺជាប្រភេទអាហារូបករណ៍ដែលទទួលបានការឧបត្ថម្ភជាសាច់ប្រាក់ចំនួន ៦០ ដុល្លារអាមេរិច ក្នុង១ខែ សម្រាប់រយៈពេល ១០ខែ ក្នុងមួយឆ្នាំសិក្សា។

**II. លក្ខខណ្ឌចុះឈ្មោះ៖**

- បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល ឬត្រូវរៀនចប់មធ្យមសិក្សាទុតិយភូមិ (ប្រឡងធ្លាក់ថ្នាក់ទី១២) ឬវិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២។

## III. កាលបរិច្ឆេទទទួលពាក្យ ៖

- បេក្ខជនត្រូវមកដាក់ពាក្យចូលរៀន ចាប់ពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ។

## IV. សំណុំលិខិតសម្រាប់ដាក់ពាក្យ ៖

បេក្ខជនត្រូវមាន ៖

- ពាក្យសុំចុះឈ្មោះ ១ ច្បាប់
- ជីវប្រវត្តិសង្ខេប ១ ច្បាប់
- រូបថត 4X6 ( ថតថ្មី ) ៣ សន្លឹក
- ច្បាប់ចម្លងសញ្ញាបត្របណ្ដោះអាសន្ន ឬព្រឹត្តិបត្រពិន្ទុ ដោយមានច្បាប់ដើមបង្ហាញ ១ ច្បាប់
- វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២ ដែលចេញដោយមន្ទីរអប់រំ យុវជន និងកីឡា រាជធានីឬខេត្ត ដែលកំពុងសិក្សា ( ចំពោះអ្នកប្រឡងធ្លាក់ថ្នាក់ទី១២ ) ១ ច្បាប់
- បង្កាន់ដៃបង់សិទ្ធិជ្រើសរើស ទឹកប្រាក់ ៨០០០ រៀល ១ ច្បាប់

ចំពោះបេក្ខជនអាទិភាពដែលជាអ្នកក្រីក្រឬរស់នៅតំបន់ជួបការលំបាកត្រូវមានសំណុំឯកសារបន្ថែម ដូចជា ៖

- ពាក្យសុំអាហារូបករណ៍ ( មានគំរូ ) ១ ច្បាប់
- សេចក្ដីបញ្ជាក់ពីភាពក្រីក្រ ឬពីការស្នាក់នៅតំបន់ជួបការលំបាកពីថ្នាក់ឃុំ/សង្កាត់ ១ ច្បាប់
- ច្បាប់ថតចម្លងប័ណ្ណគ្រួសារ ដោយមានច្បាប់ដើមបង្ហាញ ១ ច្បាប់

## V. ការចូលរៀន ៖

ការចូលរៀននឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣។

## VI. តម្លៃសិក្សាសម្រាប់និស្សិត កម្រិតបរិញ្ញាបត្ររងវិស្វកម្ម ចាប់ពីឆ្នាំសិក្សា ២០២២-២០២៣ ៖

- និស្សិតប្រុស ៖ ពីឆ្នាំទី១ ដល់ឆ្នាំទី២ តម្លៃ 300$ ក្នុង១ឆ្នាំ
- និស្សិតនារី ៖ ពីឆ្នាំទី១ ដល់ឆ្នាំទី២ តម្លៃ 200$ ក្នុង១ឆ្នាំ

<u>សេចក្ដីបញ្ជាក់</u> ៖

ចំពោះព័ត៌មានផ្សេងៗ សូមទាក់ទងទីចាត់ការសិក្សានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា **បន្ទប់លេខ** A-201 **អគារ** A **ឬតាមទូរស័ព្ទលេខ ០១២ ៦៨៣ ៤៨៣ ឬ ០១៦ ៦៥៩ ៥៣៥ ឬ ០៧១ ៨៥៤ ៤៤៣២។**

ថ្ងៃចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២

**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

Institut de Technologie du Cambodge

I.T.C

**បណ្ឌិត ប៉ូ គីមថូ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានឧត្តមសិក្សា

« ដើម្បីជូនជ្រាបជាព័ត៌មាន »

- កាលប្បវត្តិ
- ឯកសារ រ.ប.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
លេខ ១១៧៧ វ.ប.ក

# សេចក្តីជូនដំណឹងបន្ថែម

## ស្តីពីការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្រិតវិស្វករ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

**I- ចំនួនជ្រើសរើស៖**

នៅឆ្នាំសិក្សា ២០២២-២០២៣ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជានឹងធ្វើការប្រឡងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទី១ កម្រិតវិស្វករ សិក្សារយៈពេល ៥ឆ្នាំ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ ចំនួន១២០នាក់ ដែលបែងចែកតាមដេប៉ាតឺម៉ង់ដូចខាងក្រោម៖

| ដេប៉ាតឺម៉ង់ | អាហារូបករណ៍ ១០០% |
|---|---|
| ទេពកោសល្យគីមី និងអាហារ | ៣០ |
| ទេពកោសល្យសំណង់ស៊ីវិល | ៣០ |
| ទេពកោសល្យអគ្គិសនី និងថាមពល | ៣០ |
| ទេពកោសល្យឧស្សាហកម្ម និងមេកានិក | ៣០ |

**II- លក្ខខណ្ឌនៃការជ្រើសរើសជាបេក្ខជនប្រឡង ៖**

បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល។ បេក្ខជនអាចផ្តល់សញ្ញាបត្រថតចម្លងនៅពេលដាក់ពាក្យចូលរៀន។

**III- កាលបរិច្ឆេទទទួលពាក្យ និងកន្លែងទទួលពាក្យ ៖**

បេក្ខជនត្រូវមកដាក់ពាក្យដោយផ្ទាល់នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ ដែលមានទីតាំងនៅក្នុងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ **ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣**។

**IV- កាលបរិច្ឆេទនៃការប្រឡង ៖**

សម័យប្រឡងនា**ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៧:០០ព្រឹក** តទៅ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ លើវិញ្ញាសាជាភាសាខ្មែរ៖

មហាវិថី សហពន្ធ័រុស្ស៊ី ប្រអប់សំបុត្រលេខ ៨៦ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា – www.itc.edu.kh
ទូរស័ព្ទ : (855) 23 880 370 ទូរសារ : (855) 23 880 369 E-mail : info@itc.edu.kh

1. គណិតវិទ្យា រយៈពេល ២ ម៉ោង
2. តក្កវិទ្យា រយៈពេល ១ ម៉ោង
3. រូបវិទ្យា និងគីមីវិទ្យា រយៈពេល ២ ម៉ោង

បញ្ជីឈ្មោះបេក្ខជននឹងបិទផ្សាយនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ ដែលមានទីតាំងនៅក្នុងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ នា**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង១៦:០០** ព្រមទាំងបង្ហោះនៅក្នុងទំព័រ Facebook របស់វិទ្យាស្ថាន (https://www.facebook.com/itckh)។

V- **ការប្រកាសលទ្ធផលនៃការប្រឡង ៖**

ការប្រកាសលទ្ធផលប្រឡងនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១៦:០០** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ ដែលមានទីតាំងនៅក្នុងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ព្រមទាំងបង្ហោះនៅក្នុងទំព័រ Facebook របស់វិទ្យាស្ថាន (https://www.facebook.com/itckh)។

VI- **ការដាក់ពាក្យសុំចូលរៀនថ្នាក់ឆ្នាំទី១ កម្រិតវិស្វករ ៖**

ការដាក់ពាក្យចូលរៀននឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣** តទៅ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ រហូតគ្រប់ចំនួនតាមការគ្រោងទុក។

<u>សេចក្តីបញ្ជាក់៖</u>

ចំពោះព័ត៌មានផ្សេងៗ សូមទាក់ទងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាខាត្បូងឃ្មុំ ដែលមានទីតាំងនៅក្នុងសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ស្ថិតនៅក្នុងភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ឬតាមទូរស័ព្ទ ០៧៨ ៣៧៨ ៣៧៨ ឬ០៧៧ ៨៨៩ ៩៣៨ ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២២
**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

Institut de Technologie du Cambodge

**បណ្ឌិត ប៉ុ គីមថូ**

**កន្លែងទទួល៖**
- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានឧត្តមសិក្សា
  « ដើម្បីជូនជ្រាបជាព័ត៌មាន »
- វិទ្យុ-ទូរទស្សន៍ « ដើម្បីផ្សព្វផ្សាយ »
- កាលប្បវត្តិ
- ឯកសារ វ.ប.ក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

លេខ: ៦១៧០៣ វ.ប.ក

# សេចក្ដីជូនដំណឹងបន្ថែម

## ស្ដីពីការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្រិតវិស្វករ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (រាជធានីភ្នំពេញ) សម្រាប់ឆ្នាំសិក្សា ២០២២-២០២៣

I- **ចំនួនជ្រើសរើស៖**

នៅឆ្នាំសិក្សា ២០២២-២០២៣ នេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក.) នឹងជ្រើសរើសនិស្សិតចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន **កម្រិតវិស្វករ** ចំនួន ១៣០០ នាក់។

II- **អាហារូបករណ៍ ៖**

1. អាហារូបករណ៍ ១០០% ចំនួន ៨០នាក់ សម្រាប់សិក្សារយៈពេល ៥ឆ្នាំ តាមនីតិវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា។
2. អាហារូបករណ៍ ២៥% សម្រាប់និស្សិតនារីគ្រប់រូបដែលសិក្សានៅ វ.ប.ក.។
3. អាហារូបករណ៍ពីដៃគូនានា។

អាហារូបករណ៍ទាំងអស់ខាងលើនេះ នឹងត្រូវកាត់ផ្ដាច់ក្នុងករណីនិស្សិតរៀនត្រួតថ្នាក់។

III- **លក្ខខណ្ឌនៃការជ្រើសរើសជាបេក្ខជនប្រឡង ៖**

បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល។ បេក្ខជនអាចផ្ដល់សញ្ញាបត្រថតចម្លងនៅពេលដាក់ពាក្យចូលរៀន។

IV- **កាលបរិច្ឆេទទទួលពាក្យ និងកន្លែងទទួលពាក្យ ៖**

- បេក្ខជនដែលបានដាក់ពាក្យសុំធ្វើការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ពីវិទ្យាល័យ តាមនីតិវិធីកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា **ត្រូវមកបង្ហាញខ្លួននៅ វ.ប.ក. ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០២៣** ដោយភ្ជាប់មកជាមួយនូវ **សលាកប័ត្រឯកត្តជន** ចេញដោយវិទ្យាល័យ ដើម្បីផ្ទៀងផ្ទាត់និងប្រាក់ចំនួន ១២០០០រ ដើម្បីបង់សិទ្ធិប្រឡង។ ក្នុងករណីមិនបានមកបង្ហាញខ្លួន និងប្រគល់សលាកប័ត្រឯកត្តជនតាមការកំណត់ខាងលើ វ.ប.ក.នឹងចាត់ទុកថាបេក្ខជនបានបោះបង់សិទ្ធិប្រឡងរបស់ខ្លួនជាស្ថាពរ។
- ក្នុងករណីមិនបានដាក់ពាក្យសុំប្រឡងពីវិទ្យាល័យ ហើយមានបំណងសិក្សានៅ វ.ប.ក. ដោយមិនទទួលអាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា បេក្ខជនអាចមកដាក់ពាក្យប្រឡងដោយផ្ទាល់នៅ វ.ប.ក. **ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣។**



មហាវិថី សហពន្ធ័រុស្ស៊ី ប្រអប់សំបុត្រលេខ ៨៦ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា – www.itc.edu.kh
ទូរស័ព្ទ : (855) 23 880 370 ទូរសារ : (855) 23 880 369 E-mail : info@itc.edu.kh

V- **ការប្រឡងជ្រើសរើស ៖**

សម័យប្រឡងនាថ្ងៃទី**២៦ ខែមករា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៧:០០ព្រឹក** តទៅនៅវ.ប.កលើវិញ្ញាសាជាភាសាខ្មែរ ៖

1. គណិតវិទ្យា រយៈពេល ២ ម៉ោង
2. តក្កវិទ្យា រយៈពេល ១ ម៉ោង
3. រូបវិទ្យានិងគីមីវិទ្យា រយៈពេល ២ ម៉ោង

បញ្ជីឈ្មោះបេក្ខជននឹងបិទផ្សាយនា**ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣** នៅ វ.ប.ក. វេលាម៉ោង១៦:០០ ព្រមទាំងបង្ហោះនៅក្នុងទំព័រ Facebook របស់វិទ្យាស្ថាន ( https://www.facebook.com/itckh ) ។

VI- **ការប្រកាសលទ្ធផលនៃការប្រឡង ៖**

ការប្រកាសលទ្ធផលប្រឡងនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣** វេលាម៉ោង ១៦:០០ នៅ វ.ប.ក. ព្រមទាំងបង្ហោះនៅក្នុងទំព័រ Facebook របស់វិទ្យាស្ថាន ( https://www.facebook.com/itckh ) ។

VII- **ការដាក់ពាក្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្រិតវិស្វករ ៖**

ការដាក់ពាក្យចូលរៀននឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣** តទៅនៅ វ.ប.ក. រហូតគ្រប់ចំនួនតាមការគ្រោងទុក។

VIII- **តម្លៃសិក្សាសម្រាប់និស្សិតចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្រិតវិស្វករ ចាប់ពីឆ្នាំសិក្សា ២០២២-២០២៣ ៖**

- និស្សិតប្រុស ៖ ពីឆ្នាំទី១ ដល់ឆ្នាំទី៥ តម្លៃ ៦០០$ ក្នុង១ឆ្នាំ
- និស្សិតនារី ៖ ពីឆ្នាំទី១ ដល់ឆ្នាំទី៥ តម្លៃ ៤៥០$ ក្នុង១ឆ្នាំ

<u>សេចក្ដីបញ្ជាក់</u> ៖

ចំពោះព័ត៌មានផ្សេងៗ សូមទាក់ទងទីចាត់ការសិក្សានៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា **បន្ទប់លេខ** A-201 **អគារ** A **ឬតាមទូរស័ព្ទលេខ ០១២ ៦៨៣ ៤៨៣ ឬ ០១៦ ៦៥៩ ៥៣៥ ឬ ០៧១ ៨៥៤ ៤៣២។**

ថ្ងៃច័ន្ទ ៧កើត ខែកក្ដិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២

**នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

Institut de Technologie du Cambodge

I.T.C.

**បណ្ឌិត ប៉ូ គីមថូ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យក្រសួងអប់រំ យុវជន និងកីឡា
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- នាយកដ្ឋានឧត្តមសិក្សា
  « ដើម្បីជូនជ្រាបជាព័ត៌មាន »
- វិទ្យុ-ទូរទស្សន៍ « ដើម្បីផ្សព្វផ្សាយ »
- កាលប្បវត្តិ
- ឯកសារ វ.ប.ក